**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៦

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Jun-2016, 14:04
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណារបស់ យឹម ទិត្យ ស្តីពីការបកស្រាយពាក្យស័ព្ទ "ប្រជាជនស៊ីវិល" តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក**

---

**ដាក់ដោយ៖**

**សហមេធាវី**

សូ មូស្សេនី
Suzana TOMANOVIĆ

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

ជាលាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អ៊ឹម ចែម៖**

ប៊ិត ស៊ាងលីម

០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**សហចៅក្រមស៊ើបអង្កេត អោ អាន**

មុំ លុជ្ជ

Richard ROGERS
Göran SLUITER

**សហព្រះរាជអាជ្ញា មាស មុត**

អាង ឧត្តម

Michael G. KARNAVAS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង ០០៤**

០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

លោក យឹម ទិត្យ តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) ស្នើដាក់សារណាដូចខាងក្រោម ដោយអនុលោមតាម*សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី* (“សំណើសុំឲ្យដាក់សារណា”)[1] និងវិធាន ២១ នៃវិធានផ្ទៃក្នុង (“វិធាន”) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)។ នៅក្នុងសំណើសុំឲ្យដាក់សារណានេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទសួរថាតើ តាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ ការវាយប្រហាររបស់រដ្ឋ ឬអង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ផ្ទាល់ខ្លួន* អាច ឬមិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល បើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[2]។ មេធាវីការពារក្តីបានលើកឡើងថា វាក្យស័ព្ទប្រជាជនស៊ីវិល មិនបានរួមបញ្ចូលនូវសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ឬកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់អង្គការ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ("អំឡុងពេលពាក់ព័ន្ធ") ឡើយ។ មេធាវីការពារក្តីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ[3]។

## I. សារណា

### ក. ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានតាក់តែងឡើងក្រោយឆ្នាំ ១៩៤៥ ក្នុងគោលបំណងដើម្បីការពារជនស៊ីវិល និងមិនបានដោះស្រាយបញ្ហាយោធានោះទេ

1. ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (“CAH”) ត្រូវបានតាក់តែងជាលើកដំបូងបន្ទាប់ពីការកើតមាននៃអំពើឃោរឃៅ ដែលបានប្រព្រឹត្តដោយរដ្ឋណាស៊ីប្រឆាំងនឹងជនជាតិជ្វីហ្វនៅក្នុងប្រទេសអាល្លឺម៉ង់ និងប្រទេសអូទ្រីសក្នុងសង្គ្រាមលោកលើកទីពីរ[4]។ នៅពេលរដ្ឋសម្ព័ន្ធមិត្តបានពិភាក្សាពីរបៀបឆ្លើយតបទៅនឹងសកម្មភាពទាំងនេះ មានការសម្រេចថា ដោយផ្អែកលើសញ្ជាតិ

---

[1] *សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី*, ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៦, ឯកសារ D306។

[2] សំណើសុំឲ្យដាក់សារណា, កថាខណ្ឌ ៣។

[3] សារអេឡិចត្រូនិកពីអង្គភាពបកប្រែភាសាផ្ញើជូនមេធាវីការពារក្តី “ការបកប្រែញត្តិ ERN 01240540-012405 54” ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦។

[4] M Lippman,“ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”, (ឆ្នាំ ១៩៩៧)១៧ *ទិន្នានុប្បវត្តិច្បាប់គតិយលោក*, ទំព័រ ១៧៣-១៧៧។

របស់ជនរងគ្រោះ បទល្មើសទាំងនេះមិនអាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាមឡើយ។ ការកំណត់ដូច្នេះគឺដោយសារតែក្របខ័ណ្ឌច្បាប់នៃសង្គ្រាមបែបប្រពៃណី អាចអនុវត្តបានចំពោះតែប្រជាពលរដ្ឋនៃរដ្ឋផ្សេងទៀតប៉ុណ្ណោះ[5]។ ទោះជាយ៉ាងនេះក្តី ដោយសារតែទំហំ និងភាពធ្ងន់ធ្ងរនៃអំពើឃោរឃៅ គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ ("UNWCC") បានសន្និដ្ឋានថា "បទបញ្ញត្តិតូចចង្អៀត មិនត្រូវយកមកធ្វើការពិចារណានោះទេ ហើយវិសាលភាពនៃការរំលោភច្បាប់សង្គ្រាម ត្រូវពង្រីកដើម្បីបំពេញតាមតម្រូវការយុត្តិធម៌"[6]។

2. និយមន័យដំបូងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានចែងក្នុងមាត្រា៦ (គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិទីក្រុងនូរ៉ឺប៊ែក ("ធម្មនុញ្ញ IMT") ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងទីក្រុងឡុងដ៍ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ ដោយមានអត្ថន័យដូចខាងក្រោម៖

> អំពើទាំងឡាយណា ឬអំពើណាមួយក្នុងចំណោមអំពើនានាដូចខាងក្រោម គឺជាឧក្រិដ្ឋកម្មស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះ ដែលត្រូវមានការទទួលខុសត្រូវជាបុគ្គល...
> **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** មានដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល នៅមុន ឬក្នុងអំឡុងពេលនៃសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ជាតិសាសន៍ ឬសាសនា នៅក្នុងការអនុវត្ត ឬនៅក្នុងការជាប់ពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្មណាមួយដែលចិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ ទោះបីជាការរំលោភ ឬមិនរំលោភច្បាប់ក្នុងស្រុករបស់ប្រទេសដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ

---

[5] គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ, *ប្រវត្តិគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ និងការបង្កើតច្បាប់សង្គ្រាម,* គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិដោយ His Majesty's Stationary Office, ឆ្នាំ ១៩៤៨, ទំព័រ ១៧៤។

[6] គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ, *ប្រវត្តិគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ និងការបង្កើតច្បាប់សង្គ្រាម,* គណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិដោយ His Majesty's Stationary Office, ឆ្នាំ ១៩៤៨, ទំព័រ ១៧៤។

ក្តី[7]។

3. ពាក្យថា "ប្រជាជនស៊ីវិល" ត្រូវបានដាក់បញ្ចូលបន្ទាប់ពីដំណើរការធ្វើសេចក្តីព្រាងដ៏យូរអង្វែងមួយ[8]។ ការដាក់បញ្ចូលនៃវាក្យស័ព្ទនេះ ត្រូវបានពន្យល់ដោយការយោងដល់ Martens Clause សម្រាប់ធ្វើជាមូលដ្ឋានផ្លូវច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[9] និងជាភ័ស្តុតាងដែលបញ្ជាក់ថាជាបឋមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានពន្លាតចេញពីឧក្រិដ្ឋកម្មសង្គ្រាម ដោយសារបុគ្គលដែលទទួលបានការការពារស្ថិតក្នុងក្រុមតែមួយ[10]។ ប៉ុន្តែហេតុផលដ៏ចម្បងនៃការដាក់បញ្ចូលវាក្យស័ព្ទនេះគឺដើម្បីធ្វើឲ្យបទល្មើសនានាដែលរដ្ឋមួយបានប្រព្រឹត្តប្រឆាំងនឹងជនជាតិរបស់ខ្លួនក្លាយទៅជាបទល្មើសព្រហ្មទណ្ឌ[11]។

4. ក្នុងការធ្វើដូច្នេះ ពាក្យថា "ប្រជាជនស៊ីវិល" មានចេតនាមិនរាប់បញ្ចូលសមាជិកនៃកងកម្លាំងប្រដាប់អាវុធ "ទោះបីបុគ្គលទាំងនោះ ជា ឬមិនមែនជាជនស៊ីវិលដែលបានប្រយុទ្ធជាមួយកងកម្លាំងយោធារបស់សត្រូវក៏ដោយ ដោយសារការការពារបែបនេះត្រូវបានកំណត់យ៉ាងទូលំទូលាយដោយច្បាប់សង្គ្រាមជាធរមាន[12]។ ច្បាប់នេះ ក៏មិនបានរាប់បញ្ចូលសមាជិកយោធាផ្ទាល់របស់រដ្ឋ

---

[7] គម្រោង Avalon Project, *ដំណើរការសវនាការទីក្រុងនូរ៉ឺប៊ែក, វ៉ុល ១, ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ,* ថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០១៦, អាចរកបានតាមគេហទំព័រ៖ http://avalon.law.yale.edu/imt/imtconst.asp#art6.។

[8] សម្រាប់ការពិពណ៌នាពីដំណើរការធ្វើសេចក្តីព្រាងនេះ សូមមើលរបាយការណ៍របស់ RH Jackson, *តំណាងរបស់សហរដ្ឋអាមេរិកនៅក្នុងសន្និសីទអន្តរជាតិស្តីពីសវនាការយោធា,* ក្រសួងការបរទេសសហរដ្ឋអាមេរិក (វ៉ាស៊ីនតោន ឆ្នាំ ១៩៤៩)។ សូមមើលសេចក្តីអត្ថាធិប្បាយរបស់ A Cassese, *វិសាលភាពគ្របដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ,* Oxford University Press, ឆ្នាំ ២00៨, ទំព័រ ៤៦៥។

[9] M Lippman,"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", (ឆ្នាំ ១៩៩៧)១៧ *ទិន្នានុប្បវត្តិច្បាប់តតីយលោក,* ទំព័រ ១៧៣-៤។

[10] M Bassiouni,*ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ,* Kluwer Law International, ឆ្នាំ ១៩៩៩, ទំព័រ ១០។

[11] M Bassiouni, *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ,* Kluwer Law International, ឆ្នាំ ១៩៩៩, ទំព័រ ៧២។

[12] A Cassese,*វិសាលភាពគ្របដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ,* Oxford University Press, ឆ្នាំ ២00៨, ទំព័រ ៤៦៦។ ការការពារដល់កងកម្លាំងយោធារបស់សត្រូវ ត្រូវបានចែងយ៉ាងមុតមាំក្នុងលិខិតុបករណ៍នៃច្បាប់មនុស្សធម៌អន្តរជាតិ រួមទាំង "អនុសញ្ញា (iv) ដោយអនុលោមតាមវិធាន និងទំនៀមទម្លាប់នៃច្បាប់សង្គ្រាមផ្លូវគោក និងឧបសម្ព័ន្ធនៃច្បាប់នេះ", បទបញ្ញត្តិទាក់ទងនឹងវិធាន និងទំនៀមទម្លាប់នៃច្បាប់សង្គ្រាមផ្លូវគោក" (ឆ្នាំ១៩០៧)។ នៅឆ្នាំ ១៩៤៦ តុលាការយោធាអន្តរជាតិទីក្រុងនូរ៉ំ

មួយ ដែលត្រូវទទួលបានការការពារដោយច្បាប់យោធាដោយផ្ទាល់ ហេតុដូច្នេះហើយ សមាជិកយោធាទាំងនោះ មិនត្រូវការការការពារនេះឡើយ៖

> សនិទានភាពសម្រាប់វិសាលភាពមានកម្រិតនៃមាត្រា ៦(គ) [នៃធម្មនុញ្ញ IMT] គឺថា យុទ្ធជនសត្រូវ ត្រូវបានការពាររួចហើយដោយច្បាប់សង្គ្រាមតាមបែបប្រពៃណី ខណៈដែលមានការចាត់ទុកថា កងទ័ពបច្ចាមិត្រទំនងជាមិនអាចប្រព្រឹត្តអំពើឃោរឃៅប្រឆាំងនឹងយោធាផ្ទាល់ខ្លួន ឬយោធានៃប្រទេសសម្ព័ន្ធមិត្តឡើយ។ <u>នៅគ្រប់ករណីទាំងអស់ អំពើឃោរឃៅបែបនេះ ប្រសិនបើមាន នឹងត្រូវស្ថិតក្រោមយុត្តាធិការនៃតុលាការយោធារបស់ប្រទេសសាមី ហើយម្យ៉ាងវិញទៀត អំពើឃោរឃៅទាំងនេះ នឹងត្រូវស្ថិតក្រោមច្បាប់ជាតិរបស់ប្រទេសនេះ</u>[13]។

5. ទោះបីការតាក់តែងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានរំលោភអធិបតេយ្យភាពរបស់រដ្ឋ ប៉ុន្តែវាគ្របដណ្តប់តែលើលក្ខខណ្ឌចាំបាច់ក្នុងការធ្វើឱ្យអំពើដែលប្រព្រឹត្តដោយរដ្ឋណាស៊ីក្លាយទៅជាបទល្មើសព្រហ្មទណ្ឌក្នុងអំឡុងសង្គ្រាមលោកលើកទី ២ ប៉ុណ្ណោះ។ ដោយសារតែមូលហេតុនេះហើយទើបមាត្រា ៦ (គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ កម្រិតត្រឹមបទល្មើសដែលប៉ះពាល់ផលប្រយោជន៍របស់រដ្ឋដទៃ ពោលគឺបទល្មើសដែលបានប្រព្រឹត្តក្នុង ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ៖

> ជាទូទៅ នៅឆ្នាំ ១៩៤៥ ប្រទេសសម្ព័ន្ធមិត្តមិនយល់ថា ពួកគេគួរ "អនុម័តច្បាប់" ដើម្បីហាមឃាត់អំពើទាំងនោះ*ដោយមិនគិតពីផលវិបាក ឬផលប៉ះពាល់របស់វាលើរដ្ឋទីបីឡើយ*។ នៅដំណាក់កាលនោះ អ្វីដែលបានកើតឡើងក្នុងប្រព័ន្ធជាតិមួយ ដែលទោះជាផ្ទុយនឹងតម្លៃមូលដ្ឋានរបស់មនុស្សជាតិ នៅតែជាក្តីកង្វល់ដោយឡែកសម្រាប់រដ្ឋនោះ

---

ប៉ែកបានកត់សម្គាល់ថា នៅឆ្នាំ ១៩៣៩ វិធានទាំងនេះត្រូវបាន "ទទួលស្គាល់ដោយប្រទេសអរិយធម៌ទាំងអស់ និងត្រូវបានចាត់ទុកថាជាការប្រកាសទទួលស្គាល់វិធាន និងទំនៀមទម្លាប់នៃច្បាប់សង្គ្រាមផ្លូវគោក"។ សូមមើល*សាលក្រមក្នុងសំណុំរឿង Nuremberg របស់តុលាការយោធាអន្តរជាតិ ១៩៤៦ (១៩៤៧) ៤១ AJIL ១៧២*, ទំព័រ ២៤៨-២៤៩។

[13] A Cassese, វិសាលភាពគ្របដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ, Oxford University Press, ឆ្នាំ ២00៨, ទំព័រ ៤៦ (សេចក្តីបញ្ជាក់បន្ថែម)។ សូមមើលផងដែរនូវ A Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ Cassese (បោះពុម្ពលើកទី ៣)*, Oxford University Press, ឆ្នាំ ២0១៣, ទំព័រ ១0២-៣។

ប្រសិនបើវាមិនបង្កផលប៉ះពាល់ខ្លាំងលើរដ្ឋដទៃ ៖ វាស្ថិតក្នុង "ដែនយុត្តាធិការជាតិ"[14]។

6. នេះបានផ្សារភ្ជាប់ការផ្តន្ទាទោសឧក្រិដ្ឋកម្មក្រោមមាត្រា ៦ (គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិស្តីពីការផ្តន្ទាទោសអំពើផ្សេងទៀត ដែលអាចដាក់ទណ្ឌកម្មបានក្រោមលក្ខន្តិកៈនេះ ដូចជា ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ត្រូវបានធ្វើឡើងដោយយោងតាមគោលការណ៍អធិបតេយ្យភាពរបស់រដ្ឋ និងការមិនលូកដៃក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋបរទេស។ ក្នុងអំឡុងពេលចរចា ប្រធានក្រុមចរចារបស់សហរដ្ឋអាមេរិក លោក Robert H Jackson បានកត់សម្គាល់ថា ៖ "វាគឺជាគោលការណ៍ទូទៅក្នុងគោលនយោបាយការបរទេសរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកតាំងពីដើមមកដែលកំណត់ថា យើងមិនត្រូវជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋាភិបាលដទៃឡើយ...។ ប្រសិនយើងគ្មានមូលហេតុសង្គ្រាមដើម្បីលូកដៃក្នុងកិច្ចការទាំងនោះទេ យើងយល់ថា យើងគ្មានមូលដ្ឋានក្នុងការដោះស្រាយបញ្ហានេះដោយភាពសាហាវឃោរឃៅឡើយ[15]"។ យោងតាមនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានតាក់តែងឡើងក្នុងធម្មនុញ្ញ (IMT) គ្មានការរួមបញ្ចូលពាក្យ "ប្រជាជនស៊ីវិល" ឡើយ ប្រសិនបើវារំលោភបំពានអធិតេយ្យភាពរបស់រដ្ឋដោយប្រើប្រាស់កងទ័ពរបស់ខ្លួន។ បទល្មើសទាំងនេះមិនជះឥទ្ធិពលលើរដ្ឋដទៃឡើយ និងត្រូវបានកំណត់ថាស្ថិតក្នុងយុត្តាធិការនៃច្បាប់យោធារបស់រដ្ឋមួយ។

7. និយមន័យ "ដ៏វិតត្បិត" នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានអនុម័តជាបន្តបន្ទាប់ដោយមាត្រា II (គ) ក្នុងច្បាប់លេខ ១០ នៃក្រុមប្រឹក្សាគ្រប់គ្រងរបស់សម្ព័ន្ធមិត្ត (ឆ្នាំ ១៩៤៥) និងមាត្រា ៥ (គ) នៃធម្មនុញ្ញទីក្រុងតូក្យូ (ឆ្នាំ ១៩៤៦)។

---

[14] A Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ Cassese (បោះពុម្ពលើកទី ៣)*, Oxford University Press, ឆ្នាំ ២០១៣, ទំព័រ ៨៦។

[15] គម្រោង Avalon Project, *សន្និសីទអន្តរជាតិស្តីពីសវនាការយោធា ៖ ទីក្រុងឡុងដ៍ ឆ្នាំ ១៩៤៥, កំណត់ហេតុសន្និសីទថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៤៥*, ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦។ អាចរកបានតាមគេហទំព័រ ៖ http://avalon.law.yale.edu.imt/jack44.asp។ សូមមើល ការអត្ថាធិប្បាយរបស់ S Kirsch, "អំពីខុសឆ្គងពីរប្រភេទ"៖ ក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" (ឆ្នាំ ២០០៩) ២២ *ទិន្នានុប្បវត្តិ Leiden ស្តីពីច្បាប់អន្តរជាតិ*, ទំព័រ ៥៣២។

## ខ. ការអនុវត្តរបស់រដ្ឋក្រោយឆ្នាំ ១៩៤៥ និងការអត្ថាធិប្បាយមិនបានគាំទ្រការបកស្រាយទូលំទូលាយនៃពាក្យ "ប្រជាជនស៊ីវិល" ឡើយ

8. និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានពិចារណាជាច្រើនលើកច្រើនសារ បន្ទាប់មក វាត្រូវបានប្រើប្រាស់ជាលើកដំបូងក្រោយសង្គ្រាមលោកលើកទី ២។ ក្នុងអំឡុងពេលនេះ ការអនុវត្តរបស់រដ្ឋ និងការអត្ថាធិប្បាយ មិនបានគាំទ្រនិយមន័យទូលំទូលាយនៃពាក្យ "ប្រជាជនស៊ីវិល" ដើម្បីរួមបញ្ចូលសមាជិកយោធាផ្ទាល់របស់រដ្ឋមួយឡើយ។

9. គណៈកម្មការច្បាប់អន្តរជាតិ (ILC) បានពិចារណានិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដំណាក់កាលនៅចន្លោះឆ្នាំ ១៩៤៨ និង ១៩៩៦។ ក្នុងសេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥១ ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ គណៈកម្មការច្បាប់អន្តរជាតិបានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចខាងក្រោម ៖

> មាត្រា ១០ ៖ អំពើអមនុស្សធម៌ ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ឬការធ្វើទុក្ខបុកម្នេញលើ<u>ប្រជាជនស៊ីវិល</u> ដោយសារមូលហេតុសង្គម នយោបាយ ជាតិសាសន៍ ឬវប្បធម៌ដោយអាជ្ញាធររបស់រដ្ឋមួយ ឬដោយបុគ្គលឯកជន នៅពេលដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តក្នុង ឬពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀតដែលបានកំណត់ក្នុងមាត្រានេះ[16]។

10. និយមន័យនេះរួមបញ្ចូលពាក្យ "ប្រជាជនស៊ីវិល" ដែលឆ្លុះបញ្ចាំងពីនិយមន័យដែលមានចែងក្នុងមាត្រា ៦ (គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ។ សេចក្តីព្រាងនេះត្រូវបានលើកមកជជែកដេញដោលយ៉ាងផុសផុលដោយតំណាងរដ្ឋ ហើយបញ្ហានៃការពង្រីកអត្ថន័យពាក្យ "ប្រជាជនស៊ីវិល" មិនបានលេចឡើងក្នុងការអត្ថាធិប្បាយ ដែលមានភ្ជាប់ក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥១[17] ឡើយ។ ផ្ទុយទៅវិញ ការធ្វើវិសោធនកម្មចម្បង គឺសំណើសុំពង្រីកវិសាលភាពកថាខណ្ឌ

---

[16] សេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥១ ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ, អង្គការសហប្រជាជាតិ, *សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* (ឆ្នាំ ១៩៥១) វ៉ុល II ត្រង់ទំព័រ ១៣៦ (សេចក្តីបញ្ជាក់បន្ថែម)។

[17] សូមមើលការអត្ថាធិប្បាយក្នុងអត្ថបទរបស់អង្គការសហប្រជាជាតិ, *សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* (ឆ្នាំ ១៩៥១) វ៉ុល II ត្រង់ទំព័រ ១៣៦។

នេះ ដើម្បីឱ្យការដាក់ទណ្ឌកម្មលើអំពើដែលមានរៀបរាប់ក្នុងកថាខណ្ឌនោះ មិនពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀតក្នុងការតាក់តែងសេចក្តីព្រាងច្បាប់នេះ[18]។ ចំណុចនេះបង្ហាញថា ហេតុផលដំបូងនៃការពង្រីកវិសាលភាពច្បាប់សង្គ្រាម ដែលចែងដោយគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ (UNWCC) នៅឆ្នាំ ១៩៤៨ និងដែលធ្វើឱ្យមានការតាក់តែងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (CAH) ក្នុងមាត្រា ៦ (គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ ត្រូវបានបញ្ជាក់ច្បាស់នៅឆ្នាំ ១៩៥១។

11. ជាបន្តបន្ទាប់ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់ជាថ្មីក្នុងសេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥៤ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិដូចខាងក្រោម ៖

> មាត្រា ១០ ៖ អំពើអមនុស្សធម៌ ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ឬការធ្វើទុក្ខបុកម្នេញលើប្រជាជនស៊ីវិល ដោយសារមូលហេតុសង្គម នយោបាយ ជាតិសាសន៍ ឬវប្បធម៌ដោយអាជ្ញាធររបស់រដ្ឋមួយ ឬដោយបុគ្គលឯកជនក្នុងន័យញុះញង់ ឬដោយមានការអត់ឱនពីអាជ្ញាធរទាំងនោះ[19]។

12. ការធ្វើវិសោធនកម្មតែមួយគត់ដែលត្រូវបានលើកមកជជែកដេញដោល និងអនុម័តក្នុងការអត្ថាធិប្បាយដែលមានភ្ជាប់ សំដៅបញ្ជាក់ថា អំពើដែលប្រព្រឹត្តដោយបុគ្គលឯកជនត្រូវតែធ្វើឡើងក្នុងន័យញុះញង់ ឬដោយមានការអត់ឱនពីរដ្ឋមួយ[20]។ គ្មានបញ្ហាពាក់ព័ន្ធនឹងការផាត់ចោល ឬពង្រីកនិយមន័យពាក្យ “ប្រជាជនស៊ីវិល” ឡើយ។

---

[18] សេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥១ ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ, ឯកសារសម័យប្រជុំលើកទី៣ រួមមានរបាយការណ៍ពីគណៈកម្មការផ្ញើជូនមហាសន្និបាត, អង្គការសហប្រជាជាតិ, *សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* (ឆ្នាំ ១៩៥១) វ៉ុល II ត្រង់ទំព័រ ១៣៦។

[19] សេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥១៤ ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ, របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីកិច្ចការក្នុងកិច្ចប្រជុំលើកទី ៦ របស់ខ្លួនក្នុងអង្គការសហប្រជាជាតិ, *សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* (ឆ្នាំ ១៩៥៤) វ៉ុល II ត្រង់ទំព័រ ១៥០។

[20] សេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥១៤ ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ, របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីកិច្ចការក្នុងកិច្ចប្រជុំលើកទី ៦ របស់ខ្លួនក្នុងអង្គការសហប្រជាជាតិ, *សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* (ឆ្នាំ ១៩៥៤) វ៉ុល II ត្រង់ទំព័រ ១៥០។

13. ទស្សនាទានពាក់ព័ន្ធនឹង "ប្រជាជនស៊ីវិល" ត្រូវបានលុបចោលជាលើកដំបូងក្នុងសេចក្ដីព្រាងច្បាប់ឆ្នាំ ១៩៩១ ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ។ សេចក្ដីព្រាងច្បាប់នេះមិនបានរួមបញ្ចូលនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ប៉ុន្តែបានរួមបញ្ចូលបទប្បញ្ញត្តមួយដែលមានចំណងជើងថា "ការរំលោភបំពានជាប្រព័ន្ធ ឬទ្រង់ទ្រាយធំលើសិទ្ធិមនុស្ស" ដែលធ្វើឲ្យការរំលោភបំពានសិទ្ធិមនុស្សខាងក្រោមក្លាយទៅជាបទល្មើសព្រហ្មទណ្ឌ ៖

> ការធ្វើមនុស្សឃាត ទារុណកម្ម ការបង្កើត ឬការរក្សាឋានៈទាសភាព សេវភាព និងពលកម្មដោយបង្ខំលើមនុស្ស ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសង្គម នយោបាយ ជាតិសាសន៍ សាសនា ឬវប្បធម៌ជាប្រព័ន្ធ ឬក្នុងទ្រង់ទ្រាយធំ ឬការនិរទេស ឬការបង្ខំប្រជាជន ត្រូវទទួលការផ្ដន្ទាទោស......[21]។

14. សេចក្ដីព្រាងច្បាប់ឆ្នាំ ១៩៩១ ត្រូវបានស្នើឡើងក្នុងរយៈពេលជិត ២ ទសវត្សរ៍ ក្រោយអំឡុងពេលពាក់ព័ន្ធ។ ដូច្នេះ សេចក្ដីព្រាងច្បាប់នេះមិនបានឆ្លុះបញ្ចាំងពីការអនុវត្តរបស់រដ្ឋនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ក្នុងគោលបំណងបង្កើតស្ថានភាពនៃច្បាប់ទម្លាប់អន្តរជាតិ។ ម្យ៉ាងវិញទៀត សេចក្ដីព្រាងច្បាប់ឆ្នាំ ១៩៩១ បានលុបចោលទស្សនាទានពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងពិចារណា និងផ្លាស់ប្ដូរនិយមន័យពាក់ព័ន្ធនៃពាក្យ "ប្រជាជនស៊ីវិល"។ ក្នុងករណីណាក៏ដោយ "រដ្ឋនានាមិនពេញចិត្តនឹងសេចក្ដីព្រាងច្បាប់ឆ្នាំ១៩៩១ឡើយ។អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺបទបញ្ញត្តិដែលធ្វើឲ្យការរំលោភបំពានសិទ្ធិមនុស្សក្លាយទៅជាបទល្មើសព្រហ្មទណ្ឌ ផ្ដោតលើការរំលោភបំពានអធិបតេយ្យភាពរបស់រដ្ឋ[22]"។

15. បញ្ហាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានពិនិត្យឡើងវិញក្នុងសេចក្ដីព្រាងច្បាប់ឆ្នាំ ១៩៩៦ ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ។ មាត្រា ១៨ នៃសេចក្ដីព្រាងច្បាប់ឆ្នាំ ១៩៩៦ មានបទប្បញ្ញត្តមួយស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានលុបចោលពាក្យ

---

[21] សេចក្ដីព្រាងច្បាប់ឆ្នាំ ១៩៩១ ស្ដីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ, របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្ដីពីកិច្ចការក្នុងកិច្ចប្រជុំលើកទី ៤៣ របស់ខ្លួនក្នុងអង្គការសហប្រជាជាតិ, *សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មការច្បាប់អន្តរជាតិ* (ឆ្នាំ ១៩៩១) វ៉ុល II ផ្នែកទី ២ ត្រង់ទំព័រ ៧៩-៨០ ។

[22] M Boot, *អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម ៖ គោលការណ៍គ្មានច្បាប់គឺគ្មានទោស និងយុត្តាធិការជាកម្មវត្ថុរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ*, សាលាស្រាវជ្រាវសិទ្ធិមនុស្ស, ឆ្នាំ ២០០២, ទំព័រ ៤៦៦។

"ប្រជាជនស៊ីវិល"។ បរាជ័យក្នុងការពន្យល់ពីការលុបចោលពាក្យ "ប្រជាជនស៊ីវិល" ក្នុងការអត្ថាធិប្បាយដែលមានភ្ជាប់ បានគាំទ្រទស្សនៈថា ការណ៍នេះមិនមែនកើតចេញពីការវិភាគល្អិតល្អន់លើការអនុវត្តរបស់រដ្ឋក្នុងពេលបច្ចុប្បន្នឡើយ[23]។ ការលុបចោលពាក្យខាងលើក៏មិនសូវជាគួរឱ្យកត់សម្គាល់ដែរ ព្រោះវាត្រូវបានដាក់បញ្ចូលជាបន្តបន្ទាប់ទៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានអនុម័តក្នុងលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)។

16. សេចក្តីព្រាងច្បាប់របស់គណៈកម្មការច្បាប់អន្តរជាតិ និងដំណើរធ្វើសេចក្តីព្រាងច្បាប់ទាំងនេះបានលើកឡើងថា ការអនុវត្តរបស់រដ្ឋក្រោយសង្គ្រាមលោកលើកទី ២ ត្រូវអនុវត្តតាមលក្ខខណ្ឌដែលចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្តោតលើ "ប្រជាជនស៊ីវិល" និងនិយមន័យវិតត្បិតរបស់វា។ ទោះបីជាគេមានឱកាសបង្កើត និងពង្រីកនិយមន័យនេះនៅឆ្នាំ ១៩៥១ និង ១៩៥៤ ក៏ដោយ ក៏ការលើកឡើងនេះ មិនត្រូវបានបញ្ចូលក្នុងការអត្ថាធិប្បាយដែលមានភ្ជាប់ដែរ។ ប្រការនេះអាចផ្តុយស្រឡះនឹងបញ្ហាផ្សេងទៀត ដូចជា ការតម្រូវឱ្យមានទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធដែលត្រូវបានលើកមកជជែកដេញដោលយ៉ាងផុសផុលក្នុងអំឡុងពេលនេះ។ ការលើកឡើងដំបូងថា ពាក្យ "ប្រជាជនស៊ីវិល" អាចត្រូវបានផាត់ចេញ ឬបង្កើតឡើង បានលេចឡើងក្នុងសេចក្តីព្រាងច្បាប់ឆ្នាំ ១៩៩១ និង ១៩៩៦ ពោលគឺរយៈពេលជិត ២ ទសវត្សរ៍ក្រោយអំឡុងពេលពាក់ព័ន្ធ។ បញ្ហានេះមិនត្រូវបានពិចារណាដិតដល់ក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ឡើយ ហើយសេចក្តីព្រាងច្បាប់ឆ្នាំ ១៩៩១ និង ១៩៩៦ មិនសូវមានការគាំទ្រពីអន្តរជាតិនោះទេ។ ដូច្នេះ សេចក្តីព្រាងច្បាប់នេះមិនបានគូសបញ្ជាក់ពីការអនុវត្តរបស់រដ្ឋបច្ចុប្បន្ន និងមិនបានឆ្លុះបញ្ចាំងពីច្បាប់ទម្លាប់អន្តរជាតិនៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ នោះទេ។

---

[23] សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ និងការអត្ថាធិប្បាយ (ឆ្នាំ ១៩៩៦) របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីកិច្ចការក្នុងកិច្ចប្រជុំលើកទី ៤៨ របស់ខ្លួនក្នុងអង្គការសហប្រជាជាតិ, *សៀវភៅប្រចាំឆ្នាំរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ* (ឆ្នាំ ១៩៩៦) វ៉ុល II, ផ្នែកទី ២, ទំព័រ ៤៧-៥០។

**គ. មិនមានយុត្តាធិការគ្រប់គ្រាន់ក្រោយឆ្នាំ ១៩៤៥ ដើម្បីបង្កើតការអនុវត្តរបស់តុលាការច្បាស់លាស់ដែលពង្រីកអត្ថន័យពាក្យ “ប្រជាជនស៊ីវិល” ដើម្បីរួមបញ្ចូលកងទ័ពឡើយ**

17. ភាគច្រើននៃការអនុវត្តរបស់តុលាការក្រោយសង្គ្រាមលោកលើកទី២ បានប្រើប្រាស់ការបកស្រាយដោយរិតត្បិតនៃពាក្យ “ប្រជាជនស៊ីវិល” ដោយមិនរួមបញ្ចូលកងទ័ពឡើយ[24]។

18. ក្នុង *Neddermeier* សាលាឧទ្ធរណ៍ចក្រភពអង់គ្លេសប្រចាំប្រទេសអាល្លឺម៉ង់បានពិចារណាដោយផ្ទាល់ពីបុគ្គលដែលអាចក្លាយជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[25]។ សំណុំរឿងនេះពិចារណាពីឋានៈរបស់កម្មករប៉ូឡូញ ដែលចូលមកធ្វើការក្នុងប្រទេសអាល្លឺម៉ង់ក្នុងនាមជាអ្នកទោសសង្គ្រាម ប៉ុន្តែជាបន្តបន្ទាប់ ពួកគេបានបោះបង់ឋានៈនេះដោយចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ។ សាលាដំបូងបានចោទប្រកាន់ចុងចោទក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីបទធ្វើទុក្ខបុកម្នេញលើកម្មកររបស់ខ្លួន។ ក្នុងចម្លើយតបរបស់ពួកគេចំពោះបណ្តឹងឧទ្ធរណ៍របស់ចុងចោទ ប្រធានអយ្យការទទួលស្គាល់ថា ការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចជំនួសដោយឧក្រិដ្ឋកម្មសង្គ្រាម ប្រសិនបើកម្មករទាំងនោះត្រូវបានចាត់ថ្នាក់ជាអ្នកទោសសង្គ្រាម (POWs)។ យោងតាមបណ្តឹងសាទុក្ខនេះ តុលាការរកឃើញថា កម្មករទាំងនោះគឺជាអ្នកទោសសង្គ្រាម។ ដូច្នេះ តុលាការបានផ្លាស់ប្តូរការផ្តន្ទាទោសចុងចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅជាការផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម។

19. លើសពីនេះ វិធីសាស្ត្របែបរិតត្បិតចំពោះអ្នកដែលអាចក្លាយជាជនរងគ្រោះនៃឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងមនុស្សជាតិ ត្រូវបានអនុម័តដោយតុលាការពិសេសសម្រាប់បណ្តឹងសាទុក្ខរបស់ប្រទេសហូ

---

[24] A Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ Cassese (បោះពុម្ពលើកទី ៣)*, Oxford University Press, ឆ្នាំ ២០១៣, ទំព័រ ១០២-១០៣។

[25] សំណុំរឿង *Neddermeier*, តុលាការគណៈកម្មការគ្រប់គ្រងដែលត្រូវបានបង្កើតឡើងក្រោមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, សាលាឧទ្ធរណ៍, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៩ ក្នុង *តំបន់ដែលកាន់កាប់ដោយចក្រភពអង់គ្លេស-អាល្លឺម៉ង់, តុលាការគណៈកម្មការគ្រប់គ្រង, របាយការណ៍សាលាឧទ្ធរណ៍, សំណុំរឿងព្រហ្មទណ្ឌ* (ឆ្នាំ ១៩៤៨) លេខ ១, ទំព័រ ៥៨-៦០ (*Neddermeier*)។ សូមមើល, A Cassese, *The Oxford Companion to International Criminal Justice*, Oxford University Press, ឆ្នាំ ២០០៩, ទំព័រ ៨៤០។

ឡង់។ ក្នុងសំណុំរឿង *Pilz* ចុងចោទគឺជាគ្រូពេទ្យដែលមិនបានផ្តល់ការព្យាបាលដល់អ្នករងរបួសម្នាក់ និងទុកឲ្យជនរងគ្រោះស្លាប់[26]។ អ្នករងរបួសនោះមានសញ្ជាតិហូឡង់ ប៉ុន្តែជាកងទ័ពអាល្លឺម៉ង់ដូចចុងចោទដែរ។ យោងតាមបណ្តឹងសាទុក្ខនោះ តុលាការពិសេសសម្រាប់បណ្តឹងសាទុក្ខរបស់ប្រទេសហូឡង់បានពិចារណា*ក្នុងចំណោមចំណុចផ្សេងទៀត* ថាតើមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬទេ។ តុលាការបានសន្និដ្ឋានថា គ្មានការប្រព្រឹត្តឧក្រិដ្ឋកម្មនេះឡើយ ព្រោះថា "ជនរងគ្រោះមិនមែនជាប្រជាជនស៊ីវិល ហើយអំពើដែលបានប្រព្រឹត្តមិនមែនជាផ្នែកនៃការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធឡើយ[27]"។

20. ក្នុងករណីទាំងពីរនេះ តុលាការបានពិចារណាដោយផ្ទាល់ពីអត្ថន័យពាក្យ "ប្រជាជនស៊ីវិល" ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានបដិសេធការលើកឡើងថា ប្រការនេះអាចរួមបញ្ចូលកងទ័ព។ ក្នុងសំណុំរឿង *Pilz* ប្រការនេះអនុវត្តចំពោះសមាជិកយោធាអាល្លឺម៉ង់ ដោយអះអាងថាគ្មានការលើកលែងសម្រាប់សមាជិកយោធាផ្ទាល់របស់រដ្ឋមួយឡើយ។ សេចក្តីសម្រេចទាំងនេះត្រូវបានសម្រេចដោយសាលាឧទ្ធរណ៍ និងបង្ហាញពីការអនុវត្តរបស់តុលាការចក្រភពអង់គ្លេស និងតុលាការហូឡង់។ ដូច្នេះ តុលាការទាំងពីរនេះសុទ្ធតែបានឆ្លុះបញ្ចាំងពីការអនុវត្តជាប្រពៃណីក្នុងអំឡុងពេលក្រោយសង្គ្រាមលោកលើកទី ២។

21. ផ្ទុយទៅវិញ មានតែយុត្តាធិការដែលលើកឡើងពីការបកស្រាយទូលំទូលាយនៃពាក្យ "ប្រជាជនស៊ីវិល" ក្នុងអំឡុងពេលនេះប៉ុណ្ណោះ ដែលចេញពីតុលាការកំពូលអាល្លឺម៉ង់ក្នុងតំបន់ដែលកាន់កាប់ដោយចក្រភពអង់គ្លេសក្នុងសាលក្រម ៣ ដែលចេញជាបន្តបន្ទាប់។

---

[26] សំណុំរឿង Pilz, តុលាការពិសេសសម្រាប់បណ្តឹងសាទុក្ខរបស់ប្រទេសហូឡង់, សាលក្រមចេញថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៩៥០, *យុត្តាធិការរបស់ប្រទេសហូឡង់,* ឆ្នាំ ១៩៥០, លេខ ៦៨១, ទំព័រ ១២១០-១១ (*Pilz*)។ សេចក្តីសង្ខេបក្នុង A Cassese, *វិសាលភាពគ្របដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ*, Oxford University Press, ឆ្នាំ ២00៨, ទំព័រ ៩៦៦។

[27] សំណុំរឿង Pilz, តុលាការពិសេសសម្រាប់បណ្តឹងសាទុក្ខរបស់ប្រទេសហូឡង់, សាលក្រមចេញថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៩៥០, យុត្តាធិការរបស់ប្រទេសហូឡង់, ឆ្នាំ ១៩៥០, លេខ ៦៨១, ទំព័រ ១២១០-១១ (*Pilz*)។ សេចក្តីសង្ខេបក្នុង A Cassese, *វិសាលភាពគ្របដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ*, Oxford University Press, ឆ្នាំ ២00៨, ទំព័រ ៩៦៦។

22. ក្នុងសំណុំរឿង *R.* តុលាការបានផ្តន្ទាទោសសមាជិកកងកម្លាំងម្នាក់នៃរបបណាស៊ីពីបទរិះគន់មន្ត្រីគ្មានឋានន្តរសក្តិដែលពាក់ឯកសណ្ឋាន និងសមាជិក Sturmabteilung ពីបទមាក់ងាយថ្នាក់ដឹកនាំបក្សណាស៊ី។ សេចក្តីសម្រេចនេះបានធ្វើឱ្យមានការកាត់ទោសជាច្រើន ហើយមន្ត្រីនោះត្រូវបានផ្តន្ទាទោសប្រហារជីវិត។ តុលាការបានរកឃើញថា ការរិះគន់ទិតៀនអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើវាអាចបញ្ជាក់បានថា អ្នកប្រព្រឹត្តមានបំណងប្រគល់ជនរងគ្រោះឱ្យ "រចនាសម្ព័ន្ធអំណាចដែលមិនអាចគ្រប់គ្រងបានរបស់បក្ស (ណាស៊ី) និងរដ្ឋ[28]"។ ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន តុលាការមិនបានពិចារណាពីឋានៈរបស់មន្ត្រីគ្មានឋានន្តរសក្តិ ឬនិយមន័យពាក្យ "ប្រជាជនស៊ីវិល" ឡើយ។

23. ក្នុងសំណុំរឿង *P et al.* តុលាការបានផ្តន្ទាទោសសមាជិកជាច្រើននៃតុលាការយោធាពីបទឃុបឃិតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានកាត់ទោសប្រហារជីវិតកងទ័ពជើងទឹកអាល្លឺម៉ង់ ៤ នាក់ កងទ័ពម្នាក់ត្រូវបានបាននិរទេស ចំណែកកងទ័ព ៣ នាក់ទៀតត្រូវបានប្រហារជីវិត។ ក្នុងសំណុំរឿង *R.* សេចក្តីសម្រេចនេះកើតចេញពីចេតនាធ្វើឱ្យសកម្មភាពរបស់របបណាស៊ីក្លាយទៅជាបទល្មើសព្រហ្មទណ្ឌ ជាជាងសេចក្តីសម្រេចគិតទុកជាមុនក្នុងការពង្រីកវិសាលភាពគ្របដណ្តប់លើអ្នកដែលអាចក្លាយជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ តុលាការបានរកឃើញថា ទណ្ឌកម្មនេះបង្កើតបានជា "សញ្ញាណច្បាស់លាស់នៃយុត្តិធម៌បំភិតបំភ័យ និងឃោរឃៅរបស់របបណាស៊ី[29]"។

24. ចុងបញ្ចប់ ក្នុងសំណុំរឿង *H.* តុលាការបានផ្តន្ទាទោសចៅក្រមជំនុំជម្រះជនជាតិអាល្លឺម៉ង់ម្នាក់ដែលបានជំនុំជម្រះទោសមន្ត្រីកងទ័ពជើងទឹកអាល្លឺម៉ង់ ២ រូបក្នុងតុលាការយោធា។ ពីដំបូង

---

[28] សំណុំរឿង R., សេចក្តីសម្រេចចេញថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៤៨, *Entscheidungen des OberstenGerichtschofesfür die Britische Zone in Strafsachen,* ទីក្រុងប៊ែកឡាំង ឆ្នាំ ១៩៥០, វ៉ុល ១, ទំព័រ ៤៥-៩ (*R*)។ សេចក្តីសង្ខេបក្នុង A Cassese, *វិសាលភាពគ្របដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ*, Oxford University Press, ឆ្នាំ ២០០៨, ទំព័រ ៤៦៨។

[29] សំណុំរឿង P et al., *Entscheidungen des OberstenGerichtschofesfür die Britische Zone in Strafsachen,* ទីក្រុងប៊ែកឡាំង ឆ្នាំ ១៩៥០, វ៉ុល ១, ទំព័រ ២២០ (*P et al*)។ សេចក្តីសង្ខេបក្នុង A Cassese, *វិសាលភាពគ្របដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ*, Oxford University Press, ឆ្នាំ ២០០៨, ទំព័រ ៤៦៨។

ចៅក្រមរូបនេះបានកាត់ទោសប្រហារជីវិតពួកគេ ប៉ុន្តែក្រោយមក ការផ្តន្ទាទោសនេះត្រូវបានបន្ថយមកត្រឹមទោសជាប់ពន្ធនាគារ ១០ ឆ្នាំ"។ ដោយមិនបានពិចារណាពីឋានៈរបស់មន្ត្រីកងទ័ពទាំងនោះ ការផ្តន្ទាទោសសំអាងលើអង្គហេតុថា "សកម្មភាពទាំងនេះធ្វើឡើងដោយចេតនា ព្រមទាំងពាក់ព័ន្ធនឹងប្រព័ន្ធហិង្សា និងបំភិតបំភ័យរបស់របបណាស៊ី"[30]។

25. ទោះបីជាមានការដកស្រង់ញឹកញាប់ ដែលគាំទ្រការបកស្រាយទូលំទូលាយលើអត្ថន័យពាក្យ "ប្រជាជនស៊ីវិល" ក៏ដោយ ក៏វាបង្ហាញច្បាស់ថា សំណុំរឿងទាំងនេះមិនបានពិចារណាពីការបកស្រាយពាក្យនេះឡើយ[31]។ ផ្ទុយទៅវិញ សំណុំរឿងទាំងនេះត្រូវបានសម្រេចដោយផ្អែកលើបំណងធ្វើឲ្យអំពើឃោរឃៅនៃរបបណាស៊ីក្លាយទៅជាបទល្មើសព្រហ្មទណ្ឌ[32]។ យុត្តាធិការដែលកើតចេញពីសេចក្តីសម្រេចទាំងនេះ និងធ្វើឡើងដោយយោងតាមគោលនយោបាយ មិនបានឆ្លុះបញ្ចាំងពីច្បាប់ទម្លាប់អន្តរជាតិក្នុងអំឡុងពេលនេះ ឬក្នុងអំឡុងពេលពាក់ព័ន្ធឡើយ។

26. អង្គជំនុំជម្រះក្នុងសំណុំរឿង002/01 បានកត់សម្គាល់ថាមិនមានការកំណត់និយមន័យអំពី "ប្រជាជនស៊ីវិល" ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធឡើយ[33] ៖

> ដើម្បីកំណត់ថាតើប្រជាជនអាចចាត់ទុកថាជា "ជនស៊ីវិល" បានដែរ ឬយ៉ាងណា អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មិនមាននិយមន័យដែលបានកំណត់អំពីជនស៊ីវិល នៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិនោះឡើយ ក្នុងខែ មេសា ឆ្នាំ ១៩៧៥ ។ និយមន័យទូទៅនៃពាក្យថា "civilian" (ជាភាសាអង់គ្លេស) និង "civil" (ជាភាសាបារាំង) ពោលគឺសំដៅ

---

[30] សំណុំរឿង H., តុលាការកំពូលក្នុងតំបន់ដែលកាន់កាប់ដោយចក្រភពអង់គ្លេស, សាលក្រមចេញថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩, *Entscheidungen des OberstenGerichtschofesfür die Britische Zone in Strafsachen,* វ៉ុល ២, ទំព័រ ២៣១-៤៦ (*H*)។ សេចក្តីសង្ខេបក្នុង A Cassese, *វិសាលភាពគ្រប់ដណ្តប់មនុស្សជាតិក្នុងច្បាប់អន្តរជាតិ*, Oxford University Press, ឆ្នាំ ២០០៨, ទំព័រ ៤៦៩។

[31] សូមមើល ឧ. A Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ Cassese (បោះពុម្ពលើកទី ៣),* Oxford University Press, ឆ្នាំ ២០១៣, ទំព័រ ១០២-៣។

[32] បញ្ហានេះមិនអាចសម្រេចបានតាមវិធីផ្សេងបានឡើយ ព្រោះថាមិនទាន់មានច្បាប់ព្រហ្មទណ្ឌជាតិ ឬអន្តរជាតិសម្រាប់ដាក់ទណ្ឌកម្ម ឬធ្វើឲ្យរបបមួយក្លាយទៅជាបទល្មើសព្រហ្មទណ្ឌឡើយ។

[33] សំណុំរឿង ០០២/០១, សាលក្រមសំណុំរឿង ០០២/០១ ចេញថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ E313 , , កថាខណ្ឌ ១៨៥ ។

ទៅលើបុគ្គលទាំងឡាយណាដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានសម្រេចថា នៅក្នុងរយៈពេលដែលពាក់ព័ន្ធទៅនឹងបទចោទនៅចំពោះមុខនោះថា ប្រជាជនស៊ីវិលរាប់បញ្ចូលនូវបុគ្គលទាំងឡាយណាដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬមិនមែនជាជនត្រូវបានទទួលស្គាល់ថាជាអ្នកប្រយុទ្ធ[34] ។

27. បញ្ហាថាតើសមាជិកយោធាអាចក្លាយជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬយ៉ាងណានោះ មិនត្រូវបានពិចារណាជាថ្មីម្តងទៀតឡើយ រហូតដល់មានសំណុំរឿង *Barbie* នៅឆ្នាំ ១៩៨៥ ពោលគឺរយៈពេល ១០ ឆ្នាំក្រោយអំឡុងពេលពាក់ព័ន្ធ។ ក្នុងសំណុំរឿង *Barbie* នេះ តុលាការមិនបានពិចារណាថាតើសមាជិកក្រុមប្រឆាំងនឹងបារាំង អាចត្រូវបាន ឬមិនត្រូវបានរួមបញ្ចូលក្នុងក្រុមជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចុងចោទបានចោទប្រកាន់ថាបានប្រព្រឹត្តនោះឡើយ។ សភាចោទប្រកាន់ បានចេញសេចក្តីបង្គាប់ថា ត្រូវមានសាលដីកាលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែសម្រាប់តែឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើពលរដ្ឋស៊ីវិលថ្មីហ្វប៉ុណ្ណោះ។ យោងតាមបណ្តឹងឧទ្ធរណ៍នេះ តុលាការកំពូល រកឃើញថា ៖

> យ៉ាងណាក៏ដោយ [តុលាការនេះពិចារណាថា] សាលក្រមក្នុងបណ្តឹងនេះបញ្ជាក់ថា ឧក្រិដ្ឋកម្ម "សាហាវយង់ឃ្នង" ដែលបានប្រព្រឹត្តជាប្រព័ន្ធ ឬជារួមលើមនុស្សដែលជាសមាជិក ឬអាចធ្លាប់ជាសមាជិកក្រុមប្រឆាំងបានស្តែងឡើង ដោយបុគ្គលដែលបានប្រព្រឹត្ត ដោយហេតុផលនយោបាយ នៃមនោគមវិជ្ជាសង្គមនិយមជាតិ។ ទាំងចលករដែលជំរុញជនរងគ្រោះ និងសមាជិកភាពរបស់ពួកគេក្នុងក្រុមប្រឆាំងសុទ្ធតែមិនបានផាត់ចេញលទ្ធភាពថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយចេតនា។ ក្នុងការបញ្ជាក់អះអាងទៅតាមតថភាពជាក់ស្តែង និងការផាត់ចេញពីប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនូវរាល់បទល្មើសដាក់បន្ទុកលើជនជាប់ចោទដែលបានប្រព្រឹត្តលើសមាជិក ឬអ្នកដែលអាចជាសមាជិកក្រុមប្រឆាំង សភាចោទប្រកាន់ភ័ន្តច្រឡំអត្ថន័យនិង

[34] សំណុំរឿង ០០២/០១, សាលក្រមសំណុំរឿង ០០២/០១ ចេញថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ E313 , , កថាខណ្ឌ ១៨៥ ។

វិសាលភាពនៃបទប្បញ្ញត្តដែលមានរៀបរាប់ក្នុងបណ្តឹងឧទ្ធរណ៍ទាំងនេះ[35]។

28. ក្នុងសាលក្រមនេះ តុលាការពិចារណាតែលើសមាជិកឃោធារបស់សត្រូវប៉ុណ្ណោះ។ តុលាការមិនបានលើកឡើងពីសមាជិកឃោធាផ្ទាល់របស់រដ្ឋមួយនោះទេ។ ជាមួយនឹងយុត្តាធិការដែលកើតចេញពីតុលាការកំពូលអាល្លឺម៉ង់ក្នុងតំបន់ដែលកាន់កាប់ដោយចក្រភពអង់គ្លេស ដែលត្រូវបានពិភាក្សាខាងលើ សាលក្រមនេះមិនបានពិចារណាជាក់លាក់លើនិយមន័យដ៏ត្រឹមត្រូវនៃពាក្យ "ប្រជាជនស៊ីវិល" នោះឡើយ។ ជំនួសមកវិញ សំណុំរឿងនេះត្រូវបានសម្រេចតាមរយៈការពិចារណាលើបំណងរបស់ជនជាប់ចោទ ជាជាងលើប្រភេទនៃជនរងគ្រោះ។

29. លើសពីនេះទៀត វិធីសាស្ត្រដែលត្រូវបានអនុម័តក្នុងសំណុំរឿង Barbie ត្រូវបានជូនដំណឹងដោយអង្គហេតុនានានៃសំណុំរឿងនេះ។ ជនរងគ្រោះនៅក្នុងសំណុំរឿងនេះគឺជាសមាជិករបស់ក្រុមប្រឆាំងនឹងបារាំង ដោយរួមមានទាំង Jean Moulin ដែលជាសមាជិកដ៏ល្បីល្បាញម្នាក់របស់ក្រុមប្រឆាំងនឹងបារាំងផងដែរ។ ជាទូទៅ ច្បាប់ស្តីពីមនុស្សធម៌អន្តរជាតិ នឹងការពារយុទ្ធជន*ដែលលែងប្រយុទ្ធ*។ ទោះជាយ៉ាងណា ដោយសារសំណុំរឿងនេះត្រូវបាននាំយកមកក្រោយពេលដែលព្រឹត្តិការណ៍បានកើតឡើងយ៉ាងយូរនោះ ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងស្ថិតក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ('IHL') នឹងត្រូវបានរារាំងដោយអាជ្ញាយុកាលរយៈពេល ២០ ឆ្នាំ។ ដោយសារកាលៈទេសៈទាំងនេះ វាទំនងជាថា សេចក្តីសម្រេចចិត្តគឺជាលទ្ធផលដែលកើតចេញពីការអានច្បាប់ទៅតាមគោលបំណង ហើយហេតុដូចនេះ វាមិនបានបង្ហាញពីការអនុវត្តរបស់តុលាការទូទៅក្នុងអំឡុងពេលពាក់ព័ន្ធនោះឡើយ[36]។

30. ជាចុងក្រោយ ការបកស្រាយដែលត្រឹមត្រូវចំពោះពាក្យ "ប្រជាជនស៊ីវិល" ក៏បានកើតមានផងដែរនៅក្នុងច្បាប់សម្រាប់សាលាក្តីបែបទំនើបនានារួមទាំងសាលាក្តី ICTY ហើយបើប្រយោលនោះរួមទាំងនៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ('SCSL') ផងដែរ។ សហចៅក្រម

---

[35] សំណុំរឿង Barbie, តុលាការកំពូល, សាលក្រម, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៨៥ (*Barbie*)។ សេចក្តីសង្ខេបក្នុង A Cassese, G Acquaviva M Fan និង A Whiting, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ៖ សំណុំរឿង និងការអត្ថាធិប្បាយ,* Oxford University Press, ឆ្នាំ ២០១១, ទំព័រ ១៧៤-៥។

[36] សូមមើល A Cassese, G Acquaviva, M Fan and A Whiting, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖ សំណុំរឿង និងការអត្ថាធិប្បាយ*, Oxford University Press, ឆ្នាំ ២០១១, ទំព័រ ១៧៩។

ស៊ើបអង្កេត ត្រូវតែអនុវត្តដោយប្រុងប្រយ័ត្ននៅពេលពិចារណាលើយុត្តាធិការនេះ ដោយសារវាមិនមែនជាការផ្ទុះបញ្ចាំងចាំបាច់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធនោះឡើយ។ ទោះជាយ៉ាងណា យុត្តិសាស្ត្ររបស់តុលាការ ICTY បង្ហាញថា បើទោះជានិយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" បានពង្រីកបន្ថែមទៀតនៅទសវត្សរ៍ឆ្នាំ ១៩៩០ ក្ដី ក៏វាមិនត្រូវបានរួមបញ្ចូលជាក់លាក់នូវសមាជិកកងកម្លាំងយោធាផ្ទាល់របស់រដ្ឋមួយនោះដែរ។

31. ការណ៍នេះត្រូវបានកំណត់យ៉ាងច្បាស់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY នៅក្នុងសំណុំរឿង *Martić* ដែលបានពិចារណាលើបញ្ហាចំនួនពីរ ដែលកើតឡើងពីនិយមន័យនៃពាក្យ "ប្រជាជនស៊ីវិល"។ ដំបូងឡើយមានការបញ្ជាក់ថា និយមន័យនៃពាក្យ ជនស៊ីវិល នៅក្នុងមាត្រា ៥០ នៃពិធីសារបន្ថែមទី ១ ផ្ទុះបញ្ចាំងពីនិយមន័យនៃពាក្យ ជនស៊ីវិល សម្រាប់គោលបំណងអនុវត្តមាត្រា ៥ នៃលក្ខន្តិកៈនេះ និងថា អង្គជំនុំជម្រះសាលាដំបូង មិនបានបង្កើតឲ្យមានកំហុសក្នុងអង្គហេតុដែលពាក្យថា ជនស៊ីវិល នៅក្នុងបរិបទនោះ មិនបានរួមបញ្ចូលមនុស្ស*ដែលលែងប្រយុទ្ធ* នោះទេ[37]។ ក្រោយមក អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានពង្រីកនិយមន័យនៃពាក្យ ជនស៊ីវិល តែនៅក្នុងបរិបទមួយប៉ុណ្ណោះ ដោយអង្គហេតុថា យុទ្ធជន*ដែលលែងប្រយុទ្ធ* អាចជាជនរងគ្រោះពីឧប្បត្តិហេតុឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាន "លុះត្រាតែរាល់លក្ខខណ្ឌចាំបាច់ផ្សេងៗត្រូវបានឆ្លើយតប ជាពិសេស គឺថាអំពើស្ថិតក្នុងមន្ទិលសង្ស័យ គឺជាផ្នែកមួយនៃការរីករាលដាល ឬការវាយប្រហារជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល"[38]។ គំរូអង្គហេតុនៅក្នុងសំណុំរឿងនេះពិចារណាតែលើយុទ្ធជន

---

[37] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, សំណុំរឿង *Prosecutor v. Milan Martić* លេខ IT-95-11-A, សាលក្រមតុលាការឧទ្ធរណ៍, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨, កថាខណ្ឌ ៣០២ (*'Martić'*)។

[38] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, សំណុំរឿង *Prosecutor v. Milan Martić* លេខ IT-95-11-A, សាលក្រមតុលាការឧទ្ធរណ៍, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨, កថាខណ្ឌ ៣១៣ (*'Martić'*)។ ដោយគាំទ្រដល់វិធីសាស្ត្រនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដកស្រង់ច្បាប់សំណុំរឿងពីតុលាការកំពូលក្នុងតំបន់ដែលកាន់កាប់ដោយចក្រភពអង់គ្លេស និងសំណុំរឿង *Barbie* ដែលបានពិភាក្សាខាងលើ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក៏ពឹងផ្អែកលើសំណុំរឿងចំនួនពីរផងដែរ ដែលត្រូវបានសម្រេចដោយតុលាការយោធាអាមេរិកនៅទីក្រុងនូរ៉េប៊ែក: សំណុំរឿង *United States v. Wilhelm von Leeb et al.*, (*'សំណុំរឿងទីបញ្ជាការដ្ឋានជាន់ខ្ពស់'*), សាលក្រមនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៤៨, តុលាការយោធាទី V, របាយការណ៍ច្បាប់នៃតុលាការឧក្រិដ្ឋកម្មសង្គ្រាម, វ៉ុល XI និងសំណុំរឿង *United States v. Ernst Von Weizsaecker et al.*, (*'សំណុំរឿងក្រសួង'*), សាលក្រមនៅថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៤៩, តុលាការយោធាទី IV, របាយការណ៍ច្បាប់នៃតុលាការឧក្រិដ្ឋ

ដែលជាសត្រូវ *ដែលលែងប្រយុទ្ធ*។ ហេតុដូចនេះមិនអាចសន្និដ្ឋានបាននោះទេថា ការណ៍នេះអនុវត្តលើរាល់យុទ្ធជនប្រភេទនេះទាំងអស់នោះ។

32. ផ្ទុយមកវិញបញ្ហានៃការវាយប្រហារទៅលើសមាជិកយោធាផ្ទាល់របស់រដ្ឋមួយ ពិតជាកើតមានឡើងនៅក្នុងសំណុំរឿង *RUF* មុនពេលមានតុលាការ SCSL[39]។ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើការសម្លាប់ 'Kayioko' ដែលជាសមាជិក *ដែលលែងប្រយុទ្ធ* របស់ AFRC ដែលបានប្រយុទ្ធរួមជាមួយនឹង RUF នៅក្នុងជម្លោះប្រដាប់អាវុធ។ បើទោះជាលក្ខន្តិកៈរបស់តុលាការ SCSL មានចែងពីបទប្បញ្ញត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងមាត្រា ២ ក្តី ក៏អំពើនេះត្រឹមតែត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មហិង្សាសង្គ្រាមប្រឆាំងនឹងជីវិតប៉ុណ្ណោះ ជាជាងចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បញ្ហានេះត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង ដែលបានរកឃើញថា វាគឺជា "ច្បាប់មិនស៊ីជម្រៅ ដែលក្រុមប្រដាប់អាវុធមួយ មិនអាចចាប់សមាជិកផ្ទាល់របស់ខ្លួនធ្វើជាអ្នកទោសសង្គ្រាម" បាននោះទេ ហើយហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា ការសម្លាប់នេះមិនធ្លាក់ចូលទៅក្នុងដែនអំណាចនៃច្បាប់ស្តីពីមនុស្សធម៌អន្តរជាតិនោះឡើយ។ អ្វីដែលសំខាន់នោះ អង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងថាអំពើនេះអាចចូលរួមចំណែកដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយនោះទេ។ ការណ៍នេះគាំទ្រដល់ការលើកឡើងថា គិតត្រឹមឆ្នាំ ២០០៩ និយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" មិនបានពង្រីកដើម្បីរួមបញ្ចូលសមាជិក *ដែលលែងប្រយុទ្ធ* របស់កងកម្លាំងយោធាផ្ទាល់របស់រដ្ឋមួយនៅឡើយ។

---

កម្មសង្គ្រាម, វ៉ុល XIV។ សំណុំរឿងទាំងនេះ មិនពិចារណាដោយផ្ទាល់លើនិយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" នោះឡើយ។ បើទោះជាគំរូអង្គហេតុដែលត្រូវបានលើកឡើងនៅក្នុងសាលក្រម រួមបញ្ចូលការវាយប្រហារលើប្រជាជន ដែលរួមបញ្ចូលទាំងជនស៊ីវិល និងបុគ្គលិកយោធា *ដែលលែងប្រយុទ្ធ*ក្តី ក៏តុលាការមិនធ្វើការវិភាគ ឬបង្កើតអង្គហេតុលើនិយមន័យច្បាប់នៃពាក្យ "ប្រជាជនស៊ីវិល" នោះឡើយ។

[39] តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, សំណុំរឿង *Prosecutor v. Issa Hassan Sesay, Morris Kallon, Augustine Gbao,* លេខ SCSL-04-15-A, សាលក្រមអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៩, កថាខណ្ឌ ១៤៥១-៣ (*'RUF'*)។ ចូរកត់សម្គាល់ថា បញ្ហានេះមិនត្រូវបានលើកយកមកពិចារណានៅសាលាឧទ្ធរណ៍នោះឡើយ។

**ឃ. ការផ្តាច់ចេញពីគ្នានូវទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធមិនបានពង្រីកនិយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" ដើម្បីរួមបញ្ចូលសមាជិកកងកម្លាំងផ្ទាល់របស់រដ្ឋមួយនោះឡើយ**

33. មានការលើកឡើងថា ផលវិបាកមួយនៃការផ្តាច់ចេញពីគ្នានូវទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ គឺជាសេរីភាវូនីយកម្មនៃការទាមទារដ៏ទទូចថាមានតែជនស៊ីវិលប៉ុណ្ណោះ ដែលអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការណ៍នេះត្រូវបានលើកឡើងដោយ Cassese ដែលពិពណ៌នាថាវាគឺជា៖ "និន្នាការមួយឆ្ពោះទៅរកការបន្ធូរបន្ថយលក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹង ដែលជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រភេទឃាតកម្មប្រឆាំងមនុស្សជាតិ គឺជាជនស៊ីវិល ប៉ុន្តែក៏បានបន្តរហូតមកដល់ពេលថ្មីៗនេះ"[40]។ ដោយគាំទ្រដល់ការលើកឡើងនេះ Cassese ដកស្រង់យុត្តាធិការរបស់តុលាការកំពូលអាល្លឺម៉ង់ក្នុងតំបន់ដែលកាន់កាប់ដោយចក្រភពអង់គ្លេស និងសំណុំរឿង *Barbie* ដែលបានពិភាក្សាខាងលើ។

34. "និន្នាការមួយឆ្ពោះទៅរកការបន្ធូរបន្ថយ" មិនគ្រប់គ្រាន់នោះទេ ដើម្បីបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធ។ ជាពិសេស ប្រសិនបើនិន្នាការបែបគោលបំណងនេះ មានមូលដ្ឋានលើយុត្តាធិការដែលនៅមានកម្រិត និងមិនទទួលបានការគាំទ្រពីការអនុវត្ត ឬការអត្ថាធិប្បាយរបស់រដ្ឋ ដែលមិនលើកឡើងដោយផ្ទាល់នូវនិយមន័យត្រឹមត្រូវនៃពាក្យ "ប្រជាជនស៊ីវិល"។ កង្វះការយកចិត្តទុកដាក់ចំពោះបញ្ហានេះ អាចមានភាពផ្ទុយគ្នាពីកម្រិតនៃការអត្ថាធិប្បាយរបស់រដ្ឋ និងអ្នកសិក្សាស្រាវជ្រាវ ដែលត្រូវបានប្រមូលផ្តុំដោយទំនាក់ទំនងជម្លោះប្រដាប់អាវុធ។ ការដាក់និយមន័យដែលសាមញ្ញ និងត្រឹមត្រូវសម្រាប់ពាក្យ "ប្រជាជនស៊ីវិល" មិនត្រូវបានលើកយកមកពិភាក្សាឲ្យបានគ្រប់គ្រាន់ដោយរដ្ឋ និងអ្នកសិក្សាស្រាវជ្រាវនោះឡើយ។

35. ជាងនេះទៀត អត្ថិភាពនៃ"និន្នាការ"បែបនេះ មិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីព្រាងអំពីការចរចា និងការបង្កើតលក្ខន្តិកៈទីក្រុងរ៉ូមចុងក្រោយនោះទេ។ ការណ៍នេះមានសារៈសំខាន់ជា

---

[40] A Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់ Cassese (បោះពុម្ពលើកទី ៣)*, Oxford University Press, ឆ្នាំ ២០១៣, ទំព័រ ១០៤។

ពិសេស ដោយសារលក្ខន្តិកៈទីក្រុងរ៉ូម គឺជាលទ្ធផលនៃការចរចាពហុភាគី ដែលមានការចូលរួមពីរដ្ឋចំនួន ១៦០[41]។ ការណ៍នេះមានភាពផ្ទុយគ្នាពីនិយមន័យមុនៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានកំណត់ដោយអ្នកឈ្នះដូចក្នុងករណីធម្មនុញ្ញទីក្រុងនូរ៉ឺប៊ែក និងធម្មនុញ្ញទីក្រុងតូក្យូ ឬដោយក្រុមប្រឹក្សាសន្តិសុខដូចក្នុងករណីលក្ខន្តិកៈនៃតុលាការ ICTY និង ICTR[42]។

36. ដំណើរនៃការធ្វើសេចក្តីព្រាងលក្ខន្តិកៈទីក្រុងរ៉ូមដ៏ពិសេសមានន័យថា ដំណើរការនេះស្ថិតក្នុងដំណាក់កាលនៃកិច្ចដំណើរការ និងឆ្លុះបញ្ចាំងការអនុវត្តរបស់រដ្ឋស្របពេលជាមួយគ្នា។ ហេតុដូច្នេះ សំណេរនៅក្នុងមាត្រា ៧ បានរួមបញ្ចូលការវិវឌ្ឍដែលកើតមានឡើងស្របពេលគ្នាជាច្រើននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖ "ឧទាហរណ៍ និយមន័យនេះមិនតម្រូវឱ្យមានទំនាក់ទំនងណាមួយទៅនឹងជម្លោះប្រដាប់អាវុធ មិនតម្រូវឱ្យមានភស្តុតាងបញ្ជាក់ពីកត្តាជំរុញដោយសារការរើសអើង និងការទទួលស្គាល់ឧក្រិដ្ឋកម្មរបស់របបអាប៉ាថេត និងការបាត់ខ្លួនដោយបង្ខំដោយសារអំពើអមនុស្សធម៌នោះទេ"[43]។

37. ការរួមបញ្ចូលពាក្យ "ប្រជាជនស៊ីវិល" ត្រូវបានជជែកវែកញែកក្នុងអំឡុងពេលដំណើរការធ្វើសេចក្តីព្រាងនេះដោយរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានលើកឡើងឱ្យមានការពង្រីកនិយមន័យឱ្យដល់ពាក្យថា "ប្រជាជន"។ ទោះជាយ៉ាងណា ការលើកឡើងជាចុងក្រោយនេះត្រូវបានច្រានចោល "ដោយសារពាក្យនេះត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវនៅក្នុងនិយមន័យមុនៗ"[44]។ ហេតុដូចនេះ សំណេរចុងក្រោយនៃមាត្រា ៧ បញ្ជាក់ថា ការលុបចោលលក្ខខណ្ឌ

---

[41] D Robinson, '*ការកំណត់និយមន័យនៃពាក្យ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៅសន្និសីទទីក្រុងរ៉ូម* (ឆ្នាំ ១៩៩៩) ៩៣:១ *ទិន្នានុប្បវត្តិអាមេរិកស្តីពីច្បាប់អន្តរជាតិ*, ទំព័រ ៤៣។

[42] D Robinson, '*ការកំណត់និយមន័យនៃពាក្យ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៅសន្និសីទទីក្រុងរ៉ូម* (ឆ្នាំ ១៩៩៩) ៩៣:១ *ទិន្នានុប្បវត្តិអាមេរិកស្តីពីច្បាប់អន្តរជាតិ*, ទំព័រ ៥១។

[43] D Robinson, '*ការកំណត់និយមន័យនៃពាក្យ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៅសន្និសីទទីក្រុងរ៉ូម* (ឆ្នាំ ១៩៩៩) ៩៣:១ *ទិន្នានុប្បវត្តិអាមេរិកស្តីពីច្បាប់អន្តរជាតិ*, ទំព័រ ៥១។

[44] D Robinson, '*ការកំណត់និយមន័យនៃពាក្យ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នៅសន្និសីទទីក្រុងរ៉ូម* (ឆ្នាំ ១៩៩៩) ៩៣:១ *ទិន្នានុប្បវត្តិអាមេរិកស្តីពីច្បាប់អន្តរជាតិ*, ទំព័រ ៥១, ជើងទំព័រ ៥០។ ចូរកត់សម្គាល់ថា អ្នកនិពន្ធមានមុខងារជាលេខាធិការនៃគណៈកម្មាធិការសន្និសីទទីក្រុងរ៉ូម។

តម្រូវនៃទំនាក់ទំនងជម្លោះប្រដាប់អាវុធ មិនពង្រីកពាក្យជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលអាចកើតមាន ទៅដល់ពាក្យ ប្រជាជន នោះឡើយ។

## ង.សេចក្តីសន្និដ្ឋាន

38. សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើកឡើងថា៖ “គ្មានហេតុផលណាមួយដើម្បីគិត” ថាពាក្យ “ប្រជាជនស៊ីវិល” មិនគួររួមបញ្ចូលការវាយប្រហារលើសមាជិកយោធាផ្ទាល់របស់រដ្ឋមួយនោះទេប្រសិនបើ “យុទ្ធនាការបែបនេះបានកើតឡើងក្នុងពេល ឬបើមិនដូច្នេះទេមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធមួយនោះ”[45]។ ការពិនិត្យមើលឡើងវិញលើការអនុវត្តរបស់រដ្ឋការអត្ថាធិប្បាយ និងយុត្តាធិការគាំទ្រដល់សារណាដែលថាពាក្យ “ប្រជាជនស៊ីវិល” មិនបានរួមបញ្ចូលសមាជិកយោធាក្នុងអំឡុងពេលពាក់ព័ន្ធ។ សហចៅក្រមស៊ើបអង្កេតត្រូវតែអនុម័តការបកស្រាយដ៏មានតម្លៃមួយនៃវាក្យស័ព្ទនេះ ដើម្បីបំពេញចន្លោះប្រហោងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធ។ ការពង្រីកការបកស្រាយពាក្យនេះដើម្បីរួមបញ្ចូលសមាជិកយោធាផ្ទាល់របស់រដ្ឋមួយ នឹងជាការបកស្រាយអំពីស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិទៅតាមគោលបំណងជ្រុលហួសហេតុក្នុងពេលវេលាពាក់ព័ន្ធ។

[45] សំណើសុំឲ្យដាក់សារណា, ទំព័រ ៥។

០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

**អាស្រ័យហេតុនេះ** ដោយសារហេតុផលទាំងអស់ដែលបានលើកឡើង មេធាវីការពារក្តីសូមលើកឡើងថាពាក្យ "ប្រជាជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនបានរួមបញ្ចូលកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយ ឬស្ថាប័នមួយនោះឡើយនៅក្នុងអំឡុងពេលពាក់ព័ន្ធ។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

_________________ _____________________

សូ មូស្សេទ្ធី Suzana TOMANOVIĆ

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦